ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២១៤ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការកែសម្រួលផ្ទៃបឹងតាមោក (បឹងកប់ស្រូវ) ស្ថិតក្នុងរាជធានីភ្នំពេញ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការកំណត់ផ្ទៃបឹងតាមោក(បឹងកប់ស្រូវ) ទំហំ ៣.២៣៩,៧ ហិកតា ស្ថិតក្នុងរាជធានីភ្នំពេញ ជាសម្បត្តិសាធារណៈរបស់រដ្ឋ

## សម្រេច

**មាត្រា ១**: ត្រូវបានកាត់ផ្ទៃដីទំហំ ១៩៦,៥៦៩ ហិកតា (មួយរយកៅសិបប្រាំមួយហិកតា ហាសិបប្រាំមួយអាហាសិបប្រាំបួនសង់ទីអា) ស្ថិតនៅសង្កាត់ពញាពន់ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ដែលត្រូវបានកំណត់ក្នុងអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការកំណត់ផ្ទៃបឹងតាមោក (បឹងកប់ស្រូវ) ទំហំ ៣.២៣៩,៧ ហិកតា ស្ថិតក្នុងរាជធានីភ្នំពេញ ជាសម្បត្តិសាធារណៈរបស់រដ្ឋ ដើម្បី

ធ្វើអនុបយោគពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ទៅជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ដូចមាននិយាមកាភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ២ :** ត្រូវបានធ្វើប្រទានកម្មផ្ទៃដីទំហំ ១៩៦,៥៦៥៩ ហិកតា (មួយរយកៅសិបប្រាំមួយហិកតា ហាសិបប្រាំមួយអាហាសិបប្រាំបួនសង់ទីអា) ស្ថិតនៅសង្កាត់ពញាពន់ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ខាងលើ ជាកម្មសិទ្ធិជូនលោកស្រី អ៊ុយ បូរី និងលោកស្រី គង់ សុធី ដោយពន្ធ និងអាករផ្សេងៗជាបន្ទុករបស់រដ្ឋ។

**មាត្រា ៣ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នពាក់ព័ន្ធ អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ...ពុធ ៣ កើត ខែ...បុស្ស...ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...១៦...ខែ...ធ្នូ........ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល៖***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា៤*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ២១២ អនក្រ.បក ចុះថ្ងៃទី២៤ ខែ ធ្នូ ឆ្នាំ២០២០**
**ស្តីពីការកែសម្រួលផ្ទៃបឹងតាមោក (បឹងកប់ស្រូវ) ស្ថិតក្នុងរាជធានីភ្នំពេញ**

| ល.រ | អាប់ស៊ីស | អ័រដោនេ | ល.រ | អាប់ស៊ីស | អ័រដោនេ |
|---|---|---|---|---|---|
| ១ | 479766.038 | 1288935.565 | ៣២ | 479151.006 | 1288921.481 |
| ២ | 478804.584 | 1288450.943 | ៣៣ | 479122.034 | 1288917.909 |
| ៣ | 478796.455 | 1288227.256 | ៣៤ | 479122.828 | 1288932.594 |
| ៤ | 480005.378 | 1288173.378 | ៣៥ | 479111.319 | 1288939.737 |
| ៥ | 480016.623 | 1288475.004 | ៣៦ | 479087.109 | 1288944.897 |
| ៦ | 479991.273 | 1288475.891 | ៣៧ | 479077.584 | 1288959.978 |
| ៧ | 479923.475 | 1288677.415 | ៣៨ | 479054.169 | 1288961.565 |
| ៨ | 479890.165 | 1288662.285 | ៣៩ | 479053.375 | 1289002.047 |
| ៩ | 479321.033 | 1289469.498 | ៤០ | 479033.531 | 1289001.650 |
| ១០ | 479330.331 | 1289544.091 | ៤១ | 479029.165 | 1288934.181 |
| ១១ | 479057.000 | 1289582.000 | ៤២ | 478980.350 | 1288941.325 |
| ១២ | 478888.332 | 1289251.151 | ៤៣ | 478997.812 | 1288794.084 |
| ១៣ | 478934.130 | 1289214.200 | ៤៤ | 479018.847 | 1288795.671 |
| ១៤ | 478942.068 | 1289181.656 | ៤៥ | 479019.085 | 1288774.372 |
| ១៥ | 479015.622 | 1289176.893 | ៤៦ | 478998.976 | 1288775.431 |
| ១៦ | 479132.039 | 1289137.735 | ៤៧ | 479012.190 | 1288612.924 |
| ១៧ | 479314.924 | 1289121.576 | ៤៨ | 479796.049 | 1289012.604 |
| ១៨ | 479334.808 | 1289087.304 | ៤៩ | 479682.339 | 1289252.801 |
| ១៩ | 479333.750 | 1289065.873 | ៥០ | 479708.112 | 1289491.697 |
| ២០ | 479259.750 | 1289068.393 | ៥១ | 479496.326 | 1289521.070 |
| ២១ | 479223.767 | 1289047.756 | ៥២ | 479490.939 | 1289461.170 |
| ២២ | 479223.767 | 1289013.360 | ៥៣ | 479329.013 | 1289469.107 |
| ២៣ | 479261.867 | 1289015.477 | ៥៤ | 478885.521 | 1289245.638 |
| ២៤ | 479251.813 | 1288961.502 | ៥៥ | 478890.756 | 1289244.600 |
| ២៥ | 479288.325 | 1288959.914 | ៥៦ | 478928.129 | 1289210.866 |
| ២៦ | 479288.325 | 1288909.114 | ៥៧ | 478936.728 | 1289175.809 |
| ២៧ | 479240.171 | 1288905.410 | ៥៨ | 479014.780 | 1289170.848 |
| ២៨ | 479241.229 | 1288920.756 | ៥៩ | 479013.457 | 1289123.223 |
| ២៩ | 479193.075 | 1288912.289 | ៦០ | 478978.730 | 1289126.199 |
| ៣០ | 479185.138 | 1288942.119 | ៦១ | 478915.892 | 1289126.530 |
| ៣១ | 479150.213 | 1288932.990 | ៦២ | 478931.436 | 1289041.863 |

| | | | | | |
|---|---|---|---|---|---|
| ៦៣ | 478847.642 | 1289040.940 | ៩៥ | 478347.706 | 1288217.986 |
| ៦៤ | 478810.971 | 1289037.924 | ៩៦ | 477819.371 | 1287948.595 |
| ៦៥ | 478779.380 | 1289018.874 | ៩៧ | 477795.280 | 1287921.495 |
| ៦៦ | 478769.833 | 1289018.711 | ៩៨ | 477760.384 | 1287798.937 |
| ៦៧ | 478806.662 | 1288508.127 | ៩៩ | 477983.806 | 1287778.756 |
| ៦៨ | 478969.227 | 1288591.017 | ១០០ | 478033.336 | 1287845.378 |
| ៦៩ | 478800.819 | 1288593.551 | ១០១ | 478350.197 | 1288053.417 |
| ៧០ | 478801.877 | 1288529.522 | ១០២ | 477963.691 | 1288078.306 |
| ៧១ | 478807.369 | 1288527.559 | ១០៣ | 477971.963 | 1288092.829 |
| ៧២ | 478774.760 | 1288430.124 | ១០៤ | 477952.975 | 1288365.202 |
| ៧៣ | 478373.164 | 1288230.967 | ១០៥ | 477854.000 | 1288338.000 |
| ៧៤ | 478373.183 | 1288227.352 | ១០៦ | 477578.260 | 1288385.116 |
| ៧៥ | 478770.112 | 1288227.405 | ១០៧ | 477575.511 | 1288368.594 |
| ៧៦ | 478776.192 | 1288492.591 | ១០៨ | 477554.386 | 1288367.140 |
| ៧៧ | 478575.869 | 1288390.448 | ១០៩ | 477549.911 | 1288390.750 |
| ៧៨ | 478566.218 | 1288395.878 | ១១០ | 477364.000 | 1288423.000 |
| ៧៩ | 478556.308 | 1288529.100 | ១១១ | 477345.252 | 1288423.114 |
| ៨០ | 478776.991 | 1288527.443 | ១១២ | 477345.299 | 1288412.341 |
| ៨១ | 478544.264 | 1288529.244 | ១១៣ | 477337.362 | 1288412.341 |
| ៨២ | 478554.625 | 1288389.967 | ១១៤ | 477337.376 | 1288423.162 |
| ៨៣ | 478546.457 | 1288375.452 | ១១៥ | 477292.544 | 1288423.434 |
| ៨៤ | 478406.880 | 1288304.283 | ១១៦ | 477293.461 | 1288416.275 |
| ៨៥ | 478396.672 | 1288309.656 | ១១៧ | 477311.407 | 1288383.682 |
| ៨៦ | 478372.280 | 1288495.820 | ១១៨ | 477768.646 | 1288005.077 |
| ៨៧ | 478426.801 | 1288529.319 | ១១៩ | 477809.626 | 1287999.751 |
| ៨៨ | 478377.691 | 1288289.400 | ១២០ | 477734.418 | 1287972.140 |
| ៨៩ | 478385.302 | 1288303.858 | ១២១ | 477739.794 | 1287990.018 |
| ៩០ | 478372.256 | 1288403.595 | ១២២ | 477283.154 | 1288368.126 |
| ៩១ | 478344.828 | 1288478.954 | ១២៣ | 477265.208 | 1288400.719 |
| ៩២ | 477966.367 | 1288368.883 | ១២៤ | 477262.275 | 1288423.618 |
| ៩៣ | 477983.608 | 1288098.766 | ១២៥ | 476870.000 | 1288426.000 |
| ៩៤ | 477993.154 | 1288093.329 | ១២៦ | 476618.000 | 1288304.000 |

| | | | | | |
|---|---|---|---|---|---|
| ១២៧ | 476559.085 | 1288214.155 | ១៣៣ | 476874.824 | 1287963.732 |
| ១២៨ | 476629.924 | 1288215.650 | ១៣៤ | 477726.680 | 1287951.192 |
| ១២៩ | 476650.071 | 1288215.457 | ១៣៥ | 477050.353 | 1287878.336 |
| ១៣០ | 476651.394 | 1288148.649 | ១៣៦ | 477050.010 | 1287863.105 |
| ១៣១ | 476835.297 | 1288153.777 | ១៣៧ | 477709.818 | 1287803.505 |
| ១៣២ | 476894.669 | 1288158.222 | ១៣៨ | 477744.264 | 1287930.598 |